ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

# សូមគោរពជូន

## លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ

**តាមរយៈ** លោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ គ.ជ.ប.ជ

**កម្មវត្ថុ៖** របាយការណ៍សង្ខេប នៃការចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការវីវើលអនលូស (We World Onlus) ។

ថ្ងៃចន្ទ ៥កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង១៥ រសៀល នៅអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានប្រារព្ធពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់ រវាង គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការវីវើលអនលូស (We World Onlus) ក្នុងនោះខាងភាគី គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដឹកនាំដោយ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ខាងភាគី អង្គការ វីវើលអនលូស (We World Onlus) ដឹកនាំដោយ **លោកស្រី** SIMONA CAPOCASALE Country Representative ដោយមានការអញ្ជើញចូលរួមពី **លោកជំទាវ ឧត្តមសេនីយ៍ឯក ប៊ុណ្ណា សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង ឯកឧត្តមទីប្រឹក្សា សហការីអង្គការ វីវើលអនលូស (We World Onlus) និងមន្ត្រីពាក់ព័ន្ធ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មួយចំនួនទៀត ។

អនុស្សរណៈយោគយល់នេះ មានគោលបំណងបង្កើនកិច្ចសហប្រតិបត្តិការ រវាង គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និងអង្គការវីវើលអនលូស (We World Onlus) ក្នុងការរួមចំណែកឲ្យប្រសើរឡើងនូវសិទ្ធិ និងបរិយាកាសការងារប្រកបដោយ សន្តិសុខ និងសុវត្ថិភាព សម្រាប់ពលករទេសន្តរប្រវេសន៍កម្ពុជាដែលគ្មានជំនាញ និងមានជំនាញទាបនៅប្រទេសថៃ ជាពិសេសស្ត្រី ។

ក្នុងពិធីចុះហត្ថលេខានេះដែរ **លោកជំទាវ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានប្រសាសន៍ស្វាគមន៍យ៉ាងកក់ក្តៅចំពោះលោកស្រី តំណាងអង្គការវីវើលអនលូស និងសហការី ដែលបានបង្កើនកិច្ចសហប្រតិបត្តិការ ដើម្បីអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅក្នុងប្រទេសកម្ពុជា នេះបញ្ជាក់ឲ្យឃើញថា អង្គការវីវើលអនលូស ពិតជាបានរួមចំណែកយ៉ាងសកម្ម ក្នុងការលើកកម្ពស់សិទ្ធិការងាររបស់ពលករទេសន្តរប្រវេសន៍ និងសកម្មភាពមនុស្សធម៌នានា ។ **លោកជំទាវ** មានប្រសាសន៍បន្តថា ការចុះអនុស្សរណៈយោគយល់គ្នា រវាងភាគីទាំងពីរនាថ្ងៃនេះ នឹងអនុវត្តទៅតាមទិសដៅដែលបានកំណត់ ហើយធ្វើការចែករំលែកនូវបទពិសោធន៍ និងផ្តល់ព័ត៌មានទៅវិញទៅមក ដើម្បីប្រសិទ្ធភាពការងាររបស់ភាគីទាំងពីរ ។

**លោកស្រី** SIMONA CAPOCASALE (Country Representative) មានប្រសាសន៍ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដែលបានចំណាយពេលវេលា និងផ្តល់កិត្តិយសចុះហត្ថលេខាលើអនុស្សរណៈយោគយល់នេះ ក្នុងកិច្ចសហប្រតិបត្តិការល្អ រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការវីវើលអនលូស ។ លោកស្រី បានមានប្រសាសន៍បន្តថា កិច្ចសហប្រតិបត្តិការនេះនឹងទទួលបាននូវលទ្ធផលល្អ ទៅតាមការរំពឹងទុក ។

ពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់នេះ ត្រូវបានធ្វើឡើងចំនួន ០២ ច្បាប់ ដោយមានសរសេរជាភាសាខ្មែរ និងភាសាអង់គ្លេស ភាគីគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចុះហត្ថលេខាដោយ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ភាគីអង្គការវីវើលអនលូស ចុះហត្ថលេខាដោយ **លោកស្រី** SIMONA CAPOCASALE (Country Representative) ។

ពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់នេះ ត្រូវបានបញ្ចប់ដោយបរិយាកាសរីករាយ បន្ទាប់មកក៏មានការថតរូបជាអនុស្សាវរីយ៍រវាងភាគីពីរផងដែរ ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើសូម **លោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ ។

ថ្ងៃអង្គារ ៦កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១
**អ្នកធ្វើរបាយការណ៍**

វរសេនីយ៍ទោ. សៅ ស៊ីនួន

**សូមគោរពជូន**
**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**
មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់
ថ្ងៃអង្គារ ៦កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១
**អគ្គលេខាធិការ**

ឧត្តមសេនីយ៍ឯក រដ្ឋ.ប៊ុណ្ណា សំខាន់

បានឃើញ
15/06/21

ជូ_ប៊ុនអេង